**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោកបណ្ឌិត កៅ គឹមហួន ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៣
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## សំ រេ ច

**មាត្រា ១.-**

ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **"សាកលវិទ្យាល័យកម្ពុជា"** (The University of Cambodia) ហៅកាត់ជាភាសាខ្មែរ "ស.ក " និងហៅជា ភាសាអង់គ្លេស "UC" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និង មានទីតាំងគោលស្ថិតនៅ អាគារលេខ ១៤៥ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មាត្រា ២.-**

សាកលវិទ្យាល័យកម្ពុជា ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់ បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ។
- ថ្នាក់ បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ។
- ថ្នាក់ ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ។
- ថ្នាក់ បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេលយ៉ាងតិច ៣ឆ្នាំ ។

សាកលវិទ្យាល័យកម្ពុជា ត្រូវរៀបចំកម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣.-**

សាកលវិទ្យាល័យកម្ពុជា មានមហាវិទ្យាល័យចំនួន ០៥ វិទ្យាស្ថាន ០២ និង មជ្ឈមណ្ឌល ០២ :

១. មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និង ភាសាវិទ្យា
២. មហាវិទ្យាល័យ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា
៣. មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម
៤. មហាវិទ្យាល័យ រដ្ឋបាលសាធារណៈ និង ពាណិជ្ជសាស្ត្រ
៥. មហាវិទ្យាល័យ អប់រំ
៦. វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
៧. វិទ្យាស្ថានសិក្សាស្រាវជ្រាវជាន់ខ្ពស់
៨. មជ្ឈមណ្ឌលសិក្សាអាស៊ាន និង អាស៊ីខាងកើត
៩. មជ្ឈមណ្ឌលសិក្សាអន្តរជាតិ

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ឬ កំរិត ផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៤.-

សាកលវិទ្យាល័យកម្ពុជា ដឹកនាំដោយសាកលវិទ្យាធិការមួយរូប និង សាកលវិទ្យាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ សាកលវិទ្យាល័យមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និងសំរេចលើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ និងមានក្រុមប្រឹក្សាសិក្សាមួយមានតួនាទីពិនិត្យ និងផ្តល់យោបល់លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៥.-

លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់ បរិញ្ញាប័ត្ររង : បេក្ខជនត្រូវមានចំណេះដឹងទាបបំផុតបានសិក្សាបញ្ចប់ថ្នាក់ទី១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់ បរិញ្ញាប័ត្រ : បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រ ដែលមានតំលៃស្មើ ។
- ថ្នាក់ ម៉ាស្ទ័រ : បេក្ខជនត្រូវមានសញ្ញាប័ត្របរិញ្ញា រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់ បណ្ឌិត : បេក្ខជនត្រូវមានសញ្ញាប័ត្រម៉ាស្ទ័រ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

សាកលវិទ្យាល័យកម្ពុជា ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែល កំណត់អំពីការជ្រើសរើសនិស្សិតអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៦.-

សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យកម្ពុជា មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបំរើការងារ។
- គ្រប់គ្រងឱ្យបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្តតាម សារាចរ និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាល ។
- ធានាឱ្យបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡាឱ្យបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៧.-**

និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យកម្ពុជា និង ទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកំរិត និង តាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីសាកលវិទ្យាល័យនេះបំពេញ និង អនុវត្ត បានតាមគោលការណ៍កំណត់ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យកម្ពុជា មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

**មាត្រា ៩.-**

អនុក្រឹត្យនេះ មានប្រសិទ្ធភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

" <u>ដើម្បីជូនដំណឹង</u> "

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ